# I .ទីស្តីការគណៈរដ្ឋមន្ត្រី

## ១-អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៥

## អនុក្រឹត្យលេខ ៤១ អនក្រ.បក

ស្តីពីការបញ្ជាចំណាយឥតគ្រោងទុក ដែលមានលក្ខណៈ
ចាំបាច់ និង បន្ទាន់ របស់ក្រសួងការពារជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ :** កំណត់អោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោះស្រាយថវិកាសំរាប់ការចំណាយក្រៅគំរោងផែនការ ដែលចាត់ទុកជាការប្រញាប់របស់ក្រសួងការពារជាតិ តាមអាទិភាព ដែលមានជាលំដាប់លំដោយដូចខាងក្រោម ÷

១-ការចំណាយមានចំនួនទឹកប្រាក់ : ៨.៤៤៤.០០០.០០០៛០០ (ស្មើនឹង ៣.៣៧៧.៦០០$) សំរាប់បំពេញកង្វះការចំណាយឆ្នាំ ១៩៩៤ របស់អគ្គសេនាធិការ ។

២-ការចំណាយមានចំនួនទឹកប្រាក់ : ៧៩២.០០០$ ដុល្លារអាមេរិក សំរាប់ទូទាត់ថ្លៃទំនិញពិសេស គ្រាប់បួម ។

៣– ការចំណាយមានចំនួនទឹកប្រាក់ : ៦១៩.៨០០$ ដុល្លារអាមេរិក សំរាប់ជួសជុលអគ្គបញ្ជាការដ្ឋាន ។

៤– ការចំណាយមានចំនួនទឹកប្រាក់ : ១.៥៩៩.៥០០$ ដុល្លារអាមេរិក សំរាប់ទូទាត់ជំហានទី ១ ថ្លៃទិញយន្តហោះ L39 ចំនួន ៧ គ្រឿង និង ជួសជុលយន្តហោះ MIG 21 ចំនួន ៨ គ្រឿង ។

៥– ការចំណាយមានចំនួនទឹកប្រាក់ : ៤២៤.៦៣៣,៥០$ ដុល្លារអាមេរិក សំរាប់ទូទាត់ជំហានទី ២ និង ទី ៣ ថ្លៃទិញយន្តហោះ Y-12 ចំនួន ២ គ្រឿង ។

៦– ការចំណាយមានចំនួនទឹកប្រាក់ : ១.៤៦០.០០០$ ដុល្លារអាមេរិក សំរាប់ទិញគ្រឿងឧបករណ៍ពេទ្យបំពាក់អោយអាគារបំរើអោយការវះកាត់ នៅមន្ទីរពេទ្យព្រះកេតុមាលា ។

៧– ការចំណាយមានចំនួនទឹកប្រាក់ : ៦៧.៧៨៥$ ដុល្លារអាមេរិក សំរាប់ទិញសំភារៈប្រើប្រាស់ នៅអគ្គប ្ញាការដ្ឋាន ។

៨– ការចំណាយទឹកប្រាក់ចំនួន : ១.០០០.០០០$ ដុល្លារអាមេរិក សំរាប់សងលោកឧញ៉ា ថេង ប៊ុនម៉ា ។

សរុបទឹកប្រាក់ទាំងអស់ចំនួន : ៩.៣៤១.៣១៨,៥០$ ដុល្លារអាមេរិក (ប្រាំបួនលានបីរយសែសិបមួយពាន់ បីរយដប់ប្រាំបីដុល្លារអាមេរិក និង ហាសិបសេន) ។

**មាត្រា ២:** ចំពោះថវិកាចំណាយរបស់ក្រសួងការពារជាតិ ក្រៅពីការកំណត់ក្នុងមាត្រាខាងលើ រាជរដ្ឋាភិបាលនឹងកំណត់អោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោះស្រាយជាក្រោយ។

**មាត្រា ៣:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលការអនុវត្តន៍តាមអនុក្រឹត្យនេះអោយបានសំរេច ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *